# ប្រាក់ផ្គត់ផ្គង់អ្នកធ្វើការដែលបានប៉ះពាល់ដោយវីរុសកូរ៉ូណា (ជំងឺខូវីដ-១៩)

$450 Coronavirus (COVID-19) Test Isolation Payment - Khmer

## ប្រាក់ផ្គត់ផ្គង់អ្នកធ្វើការចំនួន $450

ប្រសិនបើអ្នកមានរោគសញ្ញាវីរុសកូរ៉ូណា អ្នកត្រូវតែធ្វើតេស្ត ហើយបន្ទាប់មកត្រូវស្នាក់នៅផ្ទះ។
ក៏ប៉ុន្តែអ្នកមិនចាំបាច់ត្រូវតែជ្រើសរើសរវាងសុខភាពរបស់សហគមន៍យើង និងការចិញ្ចឹមគ្រួសាររបស់អ្នកឡើយ។
រដ្ឋាភិបាលរដ្ឋវិចថូរៀបានប្រកាសអំពីប្រាក់ផ្គត់ផ្គង់ចំនួន $450 ដើម្បីផ្គត់ផ្គង់អ្នកធ្វើការដែលចាំបាច់ត្រូវដាក់ខ្លួនឱ្យនៅដាច់ដោយឡែកពីគេបន្ទាប់ពីបានធ្វើតេស្តរកមើលវីរុសកូរ៉ូណា - ក៏ប៉ុន្តែពួកគេពុំមានការឈប់សម្រាកសម្រាប់ពេលឈឺដែលពួកគេអាចប្រើបាន។
នេះរួមមានអ្នកធ្វើការតាមពេលម៉ោងមិនទៀងទាត់ អ្នកធ្វើការក្រោមកិច្ចសន្យា និងអស់អ្នកដែលពុំមាននៅសល់ការឈប់សម្រាកសម្រាប់ពេលឈឺ។
នរណាម្នាក់ដែលរស់នៅក្នុងរដ្ឋវិចថូរៀ អាចទទួលបានប្រាក់ផ្គត់ផ្គង់នេះ - អ្នកមិនចាំបាច់ជាពលរដ្ឋ ឬអ្នករស់នៅអចិន្ត្រៃយ៍ដើម្បីទទួលបានប្រាក់ផ្គត់ផ្គង់នេះទេ។
ប្រសិនបើអ្នកមានសិទ្ធិទទួលបាន ប្រាក់នេះនឹងជួយផ្គត់ផ្គង់អ្នកឱ្យស្នាក់នៅផ្ទះ ខណៈពេលអ្នកកំពុងរង់ចាំលទ្ធផលតេស្តរបស់អ្នក។
ប្រសិនបើអ្នកត្រូវបានគេបញ្ជាក់ថាមានវីរុសកូរ៉ូណា ឬត្រូវបានប្រាប់ថាអ្នកចាំបាច់ត្រូវដាក់ខ្លួនឱ្យនៅដាច់ដោយឡែកពីគេ ជាមនុស្សដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនរណាម្នាក់ដែលមានវីរុសកូរ៉ូណា អ្នកក៏នឹងទទួលបានប្រាក់ផ្គត់ផ្គង់សម្រាប់គ្រាលំបាកចំនួន $1500 ផងដែរ។
រដ្ឋាភិបាលរដ្ឋវិចថូរៀក៏កំពុងផ្តល់ប្រាក់ផ្គត់ផ្គង់នេះដែរ ដល់អ្នកធ្វើការដែលមានកូនអាយុក្រោម១៦ឆ្នាំដែលត្រូវបានប្រាប់ឱ្យដាក់ខ្លួននៅដាច់ដោយឡែកពីគេ។ នេះមានន័យថា ប្រសិនបើអ្នកត្រូវការថែទាំកូនៗរបស់អ្នកដែលត្រូវបានប្រាប់ឱ្យស្នាក់នៅផ្ទះ អ្នកក៏អាចទទួលបានប្រាក់ផ្គត់ផ្គង់នេះផងដែរ ប្រសិនបើអ្នកមិនអាចទៅធ្វើការ ហើយនឹងត្រូវបាត់បង់បៀវត្សរ៍។
សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីដាក់ពាក្យសុំ សូមទូរស័ព្ទទៅខ្សែទូរស័ព្ទទាន់ហេតុការណ៍ស្តីពីវីរុសកូរ៉ូណា លេខ 1800 675 398 ឬចូលមើលវិបសៃថ៍ www.dhhs.vic.gov.au/covid-19-worker-support-payment។

**To find out more information about coronavirus and how to stay safe visit DHHS.vic – Coronavirus (COVID-19) <www.dhhs.vic.gov.au/coronavirus>**

**If you need an interpreter, call 131 450**

**For information in other languages, scan the QR code or visit** DHHS.vic –Translated resources - coronavirus (COVID-19) **<https://www.dhhs.vic.gov.au/translated-resources-coronavirus-disease-covid-19>**

**For any questions**

**Coronavirus hotline 1800 675 398 (24 hours)**

**Please keep Triple Zero (000) for emergencies only**

To receive this document in another format phone 1300 651 160 using the National Relay Service 13 36 77 if required, or email Emergency Management Communications <em.comms@dhhs.vic.gov.au>.

Authorised and published by the Victorian Government, 1 Treasury Place, Melbourne. © State of Victoria, Australia, Department of Health and Human Services, 20 July 2020. Available at: DHHS.vic – Public housing restrictions: information and support <https://www.dhhs.vic.gov.au/information-and-supports-public-housing-restrictions-covid-19>